# ព្រឹត្តិបត្រព័ត៌មាន

## សាលារៀនជំនាន់ថ្មី វិទ្យាល័យ ហ៊ុន សែន ពាមជីកង

លេខ០៥ ខែឧសភា ឆ្នាំ២០២៤

ហ្វេសប៊ុកផេក៖ វិទ្យាល័យ ហ៊ុនសែន ពាមជីកងជំនាន់ថ្មី
លេខទូរសព្ទ៖ 096 7273 921/ 087 609 156
គេហទំព័រ www.pck.ngs.edu.kh
អ៊ីម៉ែល៖ ngspckhighschool@gmail.com

## មាតិកា


- តើការសរសេរកូដគឺជាអ្វី?
- ប្រឡងប្រចាំខែឧសភា
- នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងក្រុមការងារបានអញ្ជើញជួបសំណេះសំណាលជាមួយលោកគ្រូអ្នកគ្រូផ្នែកវិទ្យាសាស្ត្រ និងសិស្សានុសិស្សថ្នាក់ទី១២
- ការប្រារព្ធពិធីទិវានៃការចងចាំនៅស្រុកកងមាស ខេត្តកំពង់ចាម
- កិច្ចប្រជុំពិភាក្សាពីការងារ និងផ្សព្វផ្សាយអំពីស្តង់ដាសាលាមធ្យមសិក្សាគំរូ
- ការសំណេះសំណាលជាមួយកញ្ញា Freya Hinnigan Chambers ដែលជាអ្នកស្ម័គ្រមកពី U.S.A
- ការជួសជុលតុវិទ្យាសាស្ត្រប្រើប្រាស់ថវិកាកម្មវិធីសាលារៀនជំនាន់ថ្មី និងថវិកាសហគមន៍
- អបអរសាទរ ក្រុមកុមារី Technovation ក្នុងវិទ្យាល័យ ហ៊ុន សែន ពាមជីកងទាំង២ក្រុម ដែលបានជាប់វគ្គពាក់កណ្ដាលផ្តាច់ព្រ័ត្រកម្រិតថ្នាក់ជាតិក្នុងកម្មវិធី Technovation កម្ពុជា២០២៤
- ស្វែងយល់ពីបទពិសោធន៍លើការងារបង្រៀនផ្នែកពិសោធន៍និងការប្រើប្រាស់ឧបករណ៍ពិសោធន៍


## តើការសរសេរកូដគឺជាអ្វី?

បច្ចុប្បន្ននេះ មនុស្សគ្រប់ៗគ្នាមានទូរសព្ទស្មាតហ្វូនឬកុំព្យូទ័រ ហើយពួកគេប្រើប្រាស់វាជារៀងរាល់ថ្ងៃសម្រាប់ការទំនាក់ទំនងជាមួយមិត្តភក្តិ ចែករំលែករឿងរ៉ាវផ្សេងៗ អានព័ត៌មាន មើលវីដេអូ និងសកម្មភាពផ្សេងៗទៀតជាច្រើន។ទាំងអស់នេះសុទ្ធតែជាសមិទ្ធិផលដែលបានពីការសរសេរកូដឬក៏ការសរសេរកម្មវិធី ដែលជាជំនាញមូលដ្ឋាននៃព័ត៌មានវិទ្យា។ ជាមួយគ្នានេះដែរ ក្មេងៗដែលសរសេរកូដនឹងទទួលបានបទពិសោធន៍ពិសេស ដែលក្នុងនោះរួមមានការទំនាក់ទំនង ការគិតតក្កវិទ្យានិងការដោះស្រាយបញ្ហា។ទាំងនេះសុទ្ធសឹងតែជាជំនាញដែលមានតម្លៃនៅក្នុងសតវត្សទី២១ ដើម្បីឈានទៅរកភាពជោគជ័យនៅក្នុងពិភពបច្ចេកវិទ្យារបស់ពួកយើង។

តើការសរសេរកូដគឺជាអ្វី?

ការសរសេរកូដគឺជាដំណើរការនៃការសរសេរកូដឲ្យកុំព្យូទ័រមួយៗនិងតាមលំដាប់ដើម្បីឲ្យកម្មវិធីដំណើរការ។ ហ្គេម រថយន្ត ទូរសព្ទស្មាតហ្វូន ឬទោះបីជាម៉ាស៊ីនបោកខោអាវសុទ្ធសឹងតែប្រើការសរសេរកូដដើម្បីរៀបចំមុខងារត្រឹមត្រូវឲ្យវា។

ដូច្នេះហើយ ទើបមុខវិជ្ជាកុំព្យូទ័របានដាក់បញ្ចូលកម្មវិធីសិក្សាកូដដល់សិស្សានុសិស្សថ្នាក់ទី៧នៃវិទ្យាល័យ ហ៊ុន សែន ពាមជីកង ឱ្យសិស្សសិក្សារៀនសូត្រដែលសិក្សាពីមូលដ្ឋានគ្រឹះនៃការសរសេរកូដដែលមានភាពសាមញ្ញនិងងាយយល់។

ខាងក្រោមនេះគឺជាសកម្មភាពសិស្សរៀន Precoding educational games នៅក្នុងcode.org។










ពាមជីកង៖ នៅថ្ងៃព្រហស្បតិ៍ ៩កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹង ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ វិទ្យាល័យ ហ៊ុន សែន ពាមជីកង បានរៀបចំការប្រឡងប្រចាំខែឧសភា ដល់សិស្សានុសិស្សគ្រប់កម្រិតថ្នាក់សម្រាប់ឆ្នាំសិក្សា ២០២៣-២០២៤ នៅតាមអគារនីមួយៗដោយភាពតឹងរឹងបំផុត។ នៅតាមបន្ទប់ប្រឡងមានគណៈកម្មការអនុរក្សចំនួនពីរនាក់ និងនៅតាមអគារប្រឡងនីមួយៗមានគណៈកម្មការត្រួតពិនិត្យអគារចំនួនមួយនាក់។ សិស្សានុសិស្សបានខិតខំយ៉ាងយកចិត្តទុកដាក់ក្នុងការប្រឡងលើវិញ្ញាសានីមួយៗ និងពោរពេញដោយក្តីសង្ឃឹម និងទន្ទឹងរង់ចាំមើលលទ្ធផលប្រឡងរបស់ខ្លួន។ ការប្រឡងប្រព្រឹត្តទៅយ៉ាងល្អ សិស្សានុសិស្សគ្រប់កម្រិតថ្នាក់បានគោរពនូវបញ្ញាត្តិក្នុងពេលប្រឡងបានយ៉ាងខ្ជាប់ខ្ជួន។













# ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ប៉ូ គឹមថូ នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា(តិចណូ) និងក្រុមការងារបានអញ្ជើញជួបសំណេះសំណាលជាមួយលោកគ្រូអ្នកគ្រូផ្នែកវិទ្យាសាស្ត្រ និងសិស្សានុសិស្សថ្នាក់ទី១២



ពាមជីកង ៖ នាព្រឹកថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៤ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ប៉ូ គឹមថូ នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា(តិចណូ) និងក្រុមការងារបានអញ្ជើញជួបសំណេះសំណាលជាមួយលោកគ្រូអ្នកគ្រូផ្នែកវិទ្យាសាស្ត្រ និងសិស្សានុសិស្សថ្នាក់ទី១២ ចំនួន១៨២នាក់នៃវិទ្យាល័យ ហ៊ុន សែន ពាមជីកង ជំនាន់ថ្មី។

ក្នុងឱកាសនេះ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតបានពិនិត្យឡើងវិញពីស្ថានភាពបន្ទប់ពិសោធន៍ និងសកម្មភាពដឹកនាំការរៀន និងបង្រៀនពិសោធន៍កន្លងមក ហើយក្រុមការងារនឹងជួយផ្គត់ផ្គង់សម្ភារៈពិសោធន៍បន្ថែមទៀតក្នុងករណីខ្វះខាត និងជួយជំរុញការអភិវឌ្ឍជាបន្តបន្ទាប់ទៀតក្នុងវិទ្យាល័យ ហ៊ុន សែន ពាមជីកង។ បន្ថែមពីលើនេះ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតក៏បានឆ្លៀតឱកាសជួបសំណេះសំណាលជាមួយប្អូនៗសិស្សានុសិស្សថ្នាក់ទី១២ ដើម្បីធ្វើការណែនាំពីការជ្រើសរើសជំនាញនៅថ្នាក់សាកលវិទ្យាល័យ ជាពិសេសការត្រៀមខ្លួនចាប់យកជំនាញ និងការត្រៀមខ្លួនប្រឡងចូលសិក្សានៅវិទ្យាស្ថានបច្ចកវិទ្យាកម្ពុជា។








# ការប្រារព្ធពិធីទិវានៃការចងចាំនៅស្រុកកងមាស ខេត្តកំពង់ចាម




**ពាមជីកង៖** នាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤ ឯកឧត្តមបណ្ឌិត ជួន ជីវិន រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា បាន អញ្ជើញជាអធិបតី ក្នុងពិធីទិវានៃការចងចាំ ដែលត្រូវបានប្រារព្ធឡើងនៅស្រុកកងមាស ខេត្តកំពង់ចាម ដោយមានអ្នកចូលរួម ចំនួនជាង៦០០នាក់។ ក្នុងនោះដែរ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សនៃវិទ្យាល័យ ហ៊ុន សែន ពាមជីកង ក៏បានចូលរួមពិធី ទិវានៃការចងចាំនៅស្រុកកងមាស ខេត្តកំពង់ចាម នេះផងដែរ។

ក្នុងពិធីនេះ មានកម្មវិធីរាប់បាត្រប្រគេនព្រះសង្ឃចំនួន ៣០អង្គ ដើម្បីឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ បាត់បង់ជីវិតក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដែលក្នុងនោះមានការប្រគេនបច្ច័យ សៀវភៅពុម្ព ស្បង់ចីពរជូនព្រះសង្ឃ បច្ច័យកសាងវត្តអង្គរបាន ព្រមទាំងសម្ភារៈកីឡា និងសម្ភារៈសិក្សា។

សូមជម្រាបថា រាជរដ្ឋាភិបាលកម្ពុជា បានកំណត់យកថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤ ជាថ្ងៃបុណ្យជាតិ “ទិវាជាតិនៃការ ចងចាំ” ដើម្បីជាការរំឭកដល់ជនរងគ្រោះ និងការឈឺចាប់ពីឧក្រិដ្ឋកម្ម ដែលកើតមានក្នុងរបបកម្ពុជាប្រជាធិបតេយ្យ៕








# កិច្ចប្រជុំពិភាក្សាពីការងារ និងផ្សព្វផ្សាយអំពីស្តង់ដាសាលាមធ្យមសិក្សាគំរូ



ពាមជីកង៖ នារសៀលថ្ងៃចន្ទ ១៣កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤ គណៈនាយកវិទ្យាល័យ ហ៊ុន សែន ពាមជីកង ជំនាន់ថ្មី បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាពីការងារ និងផ្សព្វផ្សាយអំពីស្តង់ដាសាលាមធ្យមសិក្សាគំរូ។ កិច្ចប្រជុំមានការចូលរួមពីសំណាក់លោកនាយក នាយករង មន្ត្រីសម្របសម្រួលនៃអង្គការខេប បណ្ណារក្ស គិលានុបដ្ឋាយិកា  និងលោកគ្រូអ្នកគ្រូទាំងអស់នៃវិទ្យាល័យ ហ៊ុន សែន ពាមជីកង ជំនាន់ថ្មី។









# ការសំណេះសំណាលជាមួយកញ្ញា Freya Hinnigan Chambers ដែលជាអ្នកស្ម័គ្រមកពី U.S.A ស្ដីពីដំណើរការក្លឹប និងអ្វីដែលគាត់អាចជួយដល់លោកគ្រូអ្នកគ្រូ



ពាមជីកង៖ នៅថ្ងៃអង្គារ ទី២១ ខែឧសភា ឆ្នាំ២០២៤ នៅសាលប្រជុំអគារធនធាននៃវិទ្យាល័យ ហ៊ុន សែន ពាមជីកង មានពិធីសំណេះសំណាលមួយ ដែលមានអ្នកអញ្ជើញចូលរួមមាន លោកនាយករង មន្ត្រីកម្មវិធី គ្រូប្រឹក្សាគរុកោសល្យ លោកគ្រូ និងអ្នកគ្រូដឹកនាំក្លឹប បានចូលរួមជួបសំណេះសំណាលជាមួយកញ្ញា Freya Hinnigan Chambers ដែលជាអ្នកស្ម័គ្រចិត្តមកពី U.S.A ស្ដីពីដំណើរការក្លឹប និងអ្វីដែលគាត់អាចជួយដល់លោកគ្រូអ្នកគ្រូ ។ នៅក្នុងពិធីសំណេះសំណាលនេះដែលលោកគ្រូ អ្នកគ្រូដឹកនាំក្លឹបបានសួរទៅកញ្ញា Freya Hinnigan Chambers នូវសំណួរមួយចំនួនផងដែរស្ដីពីដំណោះស្រាយក្លឹប និងវិធីធ្វើឱ្យក្លឹបសិក្សាមានភាពទាក់ទាញ។ ជាមួយគ្នានេះដែរ កញ្ញា Freya Hinnigan Chambers ក៏បានផ្ដល់ជាយោបល់ និងដំណោះស្រាយខ្លះៗផងដែរ ដល់លោកគ្រូ អ្នកគ្រូ។



**កញ្ញា Freya Hinnigan Chambers**



**សកម្មភាពសួរសំណួរមួយចំនួន**



# ការជួសជុលតុវិទ្យាសាស្ត្រប្រើប្រាស់ថវិកាកម្មវិធីសាលារៀនជំនាន់ថ្មី និង ថវិកាសហគមន៍





ពាមជីកង៖ នាថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤ វិទ្យាល័យ ហ៊ុន សែន ពាមជីកង បានជួសជុលតុវិទ្យាសាស្ត្រដោយប្រើប្រាស់ថវិកាកម្មវិធីសាលារៀនជំនាន់ថ្មី និងថវិកាសហគមន៍។

# អបអរសាទរ ក្រុមកុមារី Technovation ក្នុងវិទ្យាល័យ ហ៊ុន សែន ពាមជីកង ទាំង២ក្រុមដែលបានជាប់វគ្គពាក់កណ្ដាលផ្ដាច់ព្រ័ត្រកម្រិតថ្នាក់ជាតិក្នុងកម្មវិធី Technovation កម្ពុជា២០២៤







អបអរសាទរ ក្រុមកុមារី Technovation នៃវិទ្យាល័យ ហ៊ុន សែន ពាមជីកង ក្នុងស្រុកកងមាសទាំង ២ក្រុម ដែលបានជាប់វគ្គពាក់កណ្ដាលផ្ដាច់ព្រ័ត្រកម្រិតថ្នាក់ជាតិ ក្នុងកម្មវិធី Technovation កម្ពុជា ២០២៤ ក្នុងនោះរួមមានកុមារីមកពីវិទ្យាល័យ ហ៊ុន សែន ពាមជីកង ចំនួន ២ក្រុមគឺ៖ Technology Healthy Girl និងក្រុម Mantial Health Saver

# ស្វែងយល់ពីបទពិសោធន៍លើការងារបង្រៀនផ្នែកពិសោធន៍ និងការប្រើប្រាស់ឧបករណ៍ពិសោធន៍

ពាមជីកង៖ នាព្រឹកថ្ងៃសៅរ៍ ទី២៥ ខែឧសភា ឆ្នាំ២០២៤ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ប៉ូ គឹមថូ ប្រធានក្រុមការងារគណបក្សចុះមូលដ្ឋានឃុំពាមជីកង បានចាត់តាំងក្រុមការងារបច្ចេកទេស ចំនួន 5 រូប មកពិភាក្សាជាមួយ លោកគ្រូ- អ្នកគ្រូ នៃវិទ្យាល័យ ហ៊ុន សែន ពាមជីកងចំនួន 30នាក់ ដែលមានជំនាញផ្នែក រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និង ផែនដីវិទ្យា ដើម្បីស្វែងយល់ពីបទពិសោធន៍លើការងារបង្រៀនផ្នែកពិសោធន៍ និងការប្រើប្រាស់ឧបករណ៍ពិសោធន៍ និងសំណូមពរផ្សេងៗ ដើម្បីអោយក្រុមការងារជួយដោះស្រាយ។

* សកម្មភាព៖

- សំណេះសំណាលពីបទពិសោធន៍ដែលលោកគ្រូ និងអ្នកគ្រូបានអនុវត្តកន្លងមកដូចជា:
- ចំនួនសិស្សដែលចូលក្នុងបន្ទប់ពិសោធន៍
- ចំនួនម៉ោងពិសោធន៍
- ចំនួនបន្ទប់ពិសោធន៍
- បទពិសោធន៍ក្នុងការបង្រៀនតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា
- ប្រភេទឧបករណ៍ពិសោធន៍
- ស្ថានភាពឧបករណ៍ពិសោធន៍
- ការលំបាក និងភាពងាយស្រួលនៃការប្រើប្រាស់ឧបករណ៍ពិសោធន៍
- តម្រូវការឧបករណ៍ពិសោធន៍បន្ថែម
- ការលំបាកក្នុងទាក់ទាញសិស្ស អោយមានចំណាប់អារម្មណ៍ចូលរួមការងារពិសោធន៍
- សំណូមពរសុំអោយក្រុមការងារជួយណែនាំពីរបៀបប្រើប្រាស់ឧបករណ៍ពិសោធន៍មួយចំនួន ដែលលោកគ្រូ អ្នកគ្រូ ចេះមិនទាន់ច្បាស់ និងមិនទាន់ចេះប្រើ។
- បន្ទាប់មក ក្រុមការងារបានចុះពិនិត្យបន្ទប់ពិសោធន៍ និងឧបករណ៍ជាក់ស្តែង។






